雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.168

ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7742 ថ្ងៃសុក្រ ទី 21 ខែ កញ្ញា ឆ្នាំ 2018

កម្មវិធី APP "ដើរលេងខេត្តយូនណាន" ថ្មីនឹងត្រូវប្រកាសជាផ្លូវការនៅខែតុលា

ពេលថ្មីៗនេះលោកយាន់ ឈឹងហ្វា អភិបាលខេត្តយូនណានបានសង្កត់ធ្ងន់ថា ស្ថាប័នពាក់ព័ន្ធត្រូវខិតខំប្រឹងប្រែងដើម្បីធានាឱ្យកម្មវិធីAPP "ដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង" ត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ១ ខែតុលា ឆ្នាំ ២០១៨ នេះ ។

ប្រជាជនជនជាតិទីបេត៍ កំពុងរាំរបាំយ៉ាងសប្បាយរីករាយ (រូបថតដោយ ចូវ ឆាន)

លោក បានលើកឡើងថា តាមរយៈការអភិវឌ្ឍន៍ជាបន្តបន្ទាប់ កម្មវិធី APP "ដើរលេងខេត្តយូនណាន" បានត្រូវកែលម្អជាបន្តបន្ទាប់ និងបានបន្ថែមនូវមុខងារថ្មីៗជាច្រើន ។ លោក បានបញ្ជាក់ថា វិស័យទេសចរណ៍ជាទ្រព្យសម្បត្តិរបស់ខេត្តយូនណាន ។ យូណាននឹងយកចិត្តទុកដាក់ចំពោះធនធានទេសចរណ៍ដ៏សម្បូរ និងមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍ដែលបានត្រូវកសាងឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅ ។ យូនណាននឹងខិតខំជំរុញឱ្យកម្មវិធី APP "ដើរលេងខេត្តយូនណាន" ក្លាយទៅជាវេទិកាសំខាន់សម្រាប់ផ្សព្វផ្សាយអំពីទឹកស្អាត ភ្នំស្អាត ទេសភាពស្អាត វប្បធម៌ត្រចះត្រចង់ និងការរស់នៅបែបថ្មីរបស់ប្រជាជនគ្រប់ជនជាតិនៅខេត្តយូនណាន ព្រមទាំងផ្សព្វផ្សាយអំពីទស្សនទេសចរនៅខេត្តយូនណានទាំងមូលពោលគឺ "យូនណានមានតំបន់ទេសចរណ៍តែមួយតំបន់ទេសចរណ៍នោះឈ្មោះថាខេត្តយូនណាន" ដើម្បីធ្វើឱ្យទេសចរគ្រប់ៗគ្នាអាចទស្សនាខេត្តយូនណាន ដោយប្រើទូរស័ព្ទតែមួយគ្រឿងនិងជំរុញឱ្យខេត្តយូនណានដើរឆ្ពោះទៅកាន់ពិភពលោកនិងក្លាយទៅជាទីដៅទេសចរណ៍របស់ប្រជាជននៃបណ្ដាប្រទេសនានា ។

នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០១៨កម្មវិធី APP "ដើរលេងខេត្តយូនណាន "V1.7.0 ត្រូវបានប្រកាសនិងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ។ កម្មវិធី" ដើរលេងខេត្តយូនណាន"V1.7.0 នេះបានកែលម្អមុខងារមួយចំនួន ដូចជាការរចនាទំព័រដើមការចាក់បញ្ចាំងវីដេអូផែនទីនាំផ្លូវនិងការណែនាំអំពីតំបន់ទេសចរណ៍ជាដើម ដើម្បីផ្ដល់សេវាកម្មកាន់តែល្អប្រសើរដល់ទេសចរជាតិនិងអន្តរជាតិ ។

កម្មវិធីថ្មីនេះបានបង្ហាញផ្នែកសំខាន់ពក្នុងទំព័រដើម រួមមានការណែនាំអំពីខេត្តក្រុង និងតំបន់ទេសចរណ៍ផ្សេងៗ ។ វាអាចជួយឱ្យអ្នកប្រើប្រាស់រកឃើញទីដៅត្រឹមត្រូវដោយចំណាយពេលដ៏ខ្លី ។

ផែនទីនាំផ្លូវក្នុងកម្មវិធីថ្មីនេះបានដាក់បញ្ចូលនូវមុខងារដ៏ច្រើន ដូចជាការរកទីតាំងនៃកន្លែងចតឡានបន្ទប់ទឹក និងកន្លែងលក់សំបុត្រជាដើម ហើយអាចចូលក្នុងប្រព័ន្ធនាំផ្លូវដោយចុចប៊ូតុងតែមួយ ។ មិនតែប៉ុណ្ណោះអ្នកប្រើប្រាស់អាចឆែករករមណីយដ្ឋានទេសចរណ៍ភោជនីយដ្ឋាន សណ្ឋាគារបន្ទប់ទឹកកន្លែងចតឡានផ្លូវល្បឿនលឿន និងព្រលានយន្តហោះតាមប្រព័ន្ធនេះ។

សព្វថ្ងៃក្រុមជំនាញដែលធ្វើការសិក្សាស្រាវជ្រាវនិងផលិតកម្មវិធី" ដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង" បានដាក់តាំងបាកូដនៃកម្មវិធីនេះនៅតំបន់ទេសចរណ៍សំខាន់ក្នុងខេត្តយូនណាន។ បើយកកម្មវិធីAPP "ដើរលេងខេត្តយូនណាន" ឬកម្មវិធី WECHAT ស្កេនបាកូដនេះលោកអ្នកក៏អាចមើលរូបថតនៃតំបន់ទេសចរណ៍ផ្សេងៗ និងស្ដាប់ការណែនាំអំពីតំបន់ទេសចរណ៍ជាដើម ៕

កសិដ្ឋានដាំ "ស្រូវល្អលើសលប់" របស់លោកយាន់ ឡុងភឹង ប្រមូលបានផលស្រូវ ១៧.២៨៤,៥តោនក្នុងស្រែមួយហិកតា

ប្រជាកសិករប្រមូលបានផល ស្រូវដ៏ច្រើនប្រកបដោយភាពសប្បាយរីករាយ (រូបថតដោយលី ស៊ូហ្វឹន)

នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ ២០១៨ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវស្រូវបង្កាត់ពូជខេត្តហ៊ូណាន និងមជ្ឈមណ្ឌលជាតិសិក្សាស្រាវជ្រាវស្រូវបង្កាត់ពូជបានរៀបចំសិក្ខាសាលា ស្ដីពីការបង្ហាញពូជស្រូវថ្មី ដែលអាចប្រមូលបានផលច្រើន នៅមណ្ឌលជនជាតិហានីនិងជនជាតិយី ហុងហឺ ខេត្តយូនណាន។ តាមការពិនិត្យ និងថ្លឹងទម្ងន់ផលស្រូវដែលប្រមូលបានកសិដ្ឋានដាំ "ស្រូវល្អលើសលប់" របស់លោក យាន់ ឡុងភឹង ប្រមូលបានផលស្រូវ ១៧.២៨៤,៥ តោនក្នុងស្រែមួយហិកតា ដែលបានបង្កើតឯតទគ្គកម្មថ្មីក្នុងកសិដ្ឋាននេះ ៕

ដោយ លី ស៊ូហ្វឹន

ប្រទេសចិន និងមីយ៉ាន់ម៉ាចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្ដីពីការរួមគ្នាកសាងរបៀងសេដ្ឋកិច្ចចិន-មីយ៉ាន់ម៉ា

រសៀលថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ២០១៨ លោក ហឺ លីហ្វឹង ប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ និងកែទម្រង់ជាតិនៃសាធារណរដ្ឋប្រជាមានិតចិន និង លោក អ៊ូ ជុនវិន រដ្ឋមន្ត្រីក្រសួងផែនការនិងហិរញ្ញវត្ថុប្រទេសមីយ៉ាន់ម៉ា បានតាងនាមរដ្ឋាភិបាលនៃប្រទេសទាំងពីរចុះហត្ថលេខាលើ "អនុស្សរណៈយោគយល់គ្នា ស្ដីពីការរួមគ្នាកសាងរបៀងសេដ្ឋកិច្ចរវាងប្រទេស ចិន និងមីយ៉ាន់ម៉ា"។ មុននឹងចូលរួមពិធីចុះហត្ថលេខានេះ លោក ហឺ លីហ្វឹង និង លោក អ៊ូ ជុនវិន បានជួបពិភាក្សាគ្នាអំពីការអនុវត្តចំណុចឯកភាពនៃអ្នកដឹកនាំប្រទេសទាំងពីរ និងការរួមគ្នាកសាងរបៀងសេដ្ឋកិច្ចចិន-មីយ៉ាន់ម៉ា ។

តាមការណែនាំបានឱ្យដឹងថា នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ មន្ត្រីជាន់ខ្ពស់នៃប្រទេសទាំងពីរចិន និង មីយ៉ាន់ម៉ាបានចូលរួមកិច្ចប្រជុំលើកទី១ នៃគណៈកម្មាធិការរួមអំពីការកសាងរបៀងសេដ្ឋកិច្ចរវាងប្រទេសចិន និង មីយ៉ាន់ម៉ានៅក្រុងប៉េកាំង ដើម្បីជំរុញការអនុវត្តតាមចំណុចឯកភាពគ្នារវាងលោក ស៊ី ជីនភីង ប្រធានាធិបតីចិន និងលោកជំទាវ អ៊ុងសានស៊ូជី ទីប្រឹក្សាកិច្ចការរដ្ឋនៃប្រទេសមីយ៉ាន់ម៉ា ។

ភាគីទាំងពីរបានពិគ្រោះពិភាក្សាអំពីទស្សនៈ គោលការណ៍ យន្តការការងារនៃគណៈកម្មាធិការរួម គម្រោងអាទិភាព ផែនការសហប្រតិបត្តិការ និងគម្រោងសំខាន់ៗ ហើយបានឯកភាពគ្នាលើចំណុចដ៏ច្រើន ។ ភាគីទាំងពីរបានឯកភាពលើការបង្កើតក្រុមការងារជំនាញ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ចំនួន១២ រួមមានផែនការអភិវឌ្ឍន៍ សមត្ថភាពផលិត និងវិនិយោគ គមនាគមន៍ ថាមពល កសិកម្ម សេដ្ឋកិច្ចតាមព្រំដែន ផ្លូវសូត្រឌីជីថល អេកូ-បរិស្ថាន ទេសចរណ៍ ហិរញ្ញវត្ថុ ព័ត៌មាន និងកិច្ចសហប្រតិបត្តិការតាមតំបន់មូលដ្ឋាន ។ ភាគីទាំងពីរនឹងខិតខំពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យយុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍន៍តាមរយៈយន្តការ នៃគណៈកម្មាធិការរួម ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការជាក់ស្ដែងលើគ្រប់វិស័យ ៕

គ្រឿងបរិភោគតែបងរបស់ខេត្តយូនណានទទួលការស្វាគមន៍នៅប្រទេសហ្វីលីពីន

នៅថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០១៨ ទីស្នាក់ការពាណិជ្ជកម្មនៃខេត្តយូនណានប្រចាំប្រទេសហ្វីលីពីន(ម៉ានីល)បាននាំយកផលិតផលគ្រឿងបរិភោគបៃតងសំខាន់ទាំង៨មុខដែលផលិតដោយសហគ្រាសយូនណានចំនួនជាង២០ ទៅចូលរួមពិព័រណ៍គ្រឿងបរិភោគ និងគ្រឿងភេសជ្ជៈអាស៊ីលើកទី ២២ ឆ្នាំ ២០១៨ ដែលរៀបចំនៅមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោកក្នុងទីក្រុងម៉ានីល នៃប្រទេសហ្វីលីពីន ។

សត្វតំណាងនៃពិព័រណ៍នេះកំពុងផ្សព្វផ្សាយអំពីគ្រឿងបរិភោគបៃតងរបស់ ខេត្តយូនណាន (រូបថតដោយ ក្វាន់ ស្យ៉ាងតុង)

ក្នុងពិព័រណ៍នេះ នំផ្កាស្រស់ វូណាត់ កាហ្វេ និងគ្រឿងបរិភោគបៃតង ពិសេសមួយចំនួនទៀត របស់ខេត្ត យូនណានបានត្រូវដាក់តាំងបង្ហាញជូនប្រជាជនហ្វីលីពីន ។ តាមប្រភពព័ត៌មានពាក់ព័ន្ធបានឱ្យដឹងថា សព្វថ្ងៃមានក្រុមហ៊ុនហ្វីលីពីនជាង ១០ ក្រុមហ៊ុនកំពុងពិភាក្សាជាមួយក្រុមហ៊ុនយូនណាន ដើម្បីបង្កើតកិច្ចសហការគ្នាក្នុងការលក់ផលិតផលយូនណាននៅប្រទេសហ្វីលីពីន ៕

ដោយ ក្វាន់ ស្យ៉ាងតុង

ឆ្អឹងសត្វ dinosaur ប្រភេទថ្មី មួយទៀតត្រូវរកឃើញនៅស្រុកលូហ្វឹងនៃខេត្តយូនណាន


ហ្វូស៊ីល "dinosaur យីចូវនាមត្រកូលសុន " ដែលត្រូវដាក់តាំងពិព័រណ៍ក្នុងសារមន្ទីរ "ជ្រលងភ្នំសត្វ dinosaur ស្រុកលូហ្វឹង" (រូបថតដោយ យ៉ាវ យ៉ុង)

ពេលថ្មីៗនេះ ទស្សនាវដ្ដី "របាយការណ៍វិទ្យាសាស្ត្រ" របស់ប្រទេសអង់គ្លេស ដែលជាទស្សនាវដ្ដីជំនាញល្បីឈ្មោះជាងគេក្នុងវិស័យវិទ្យាសាស្ត្រធម្មជាតិលើពិភពលោក បានចុះផ្សាយអត្ថបទថា ឆ្អឹងសត្វ dinosaur ប្រភេទថ្មីមួយទៀត ត្រូវបានរកឃើញនៅក្នុងស្រុកលូហ្វឹងនៃខេត្តយូនណាន ។ សត្វ dinosaur ប្រភេទថ្មីនេះជាសត្វប្រភេទ Sauropodiformes ហើយបានត្រូវគេដាក់ឈ្មោះថា "dinosaur យីចូវ នាមត្រកូលសុន" ដើម្បីរំលឹកវិញ្ញាណក្ខន្ធរបស់លោកស្រីសុន អៃលីង ដែលជាអ្នកវិទ្យាសាស្ត្រសិក្សាស្រាវជ្រាវសត្វបុរាណល្បីឈ្មោះមួយរូបក្នុងប្រទេសចិន ។ នេះជាការរកឃើញដ៏សំខាន់មួយទៀត នៅស្រុកលូហ្វឹងនៃខេត្តយូនណាន ក្រោយពីបានរកឃើញឆ្អឹងសត្វ dinosaur "Xingxiulong chengi" ៕

ដោយ យ៉ាវ យ៉ុង

ជិះរថភ្លើងល្បឿនលឿនពីក្រុងគុនមីងទៅតំបន់ហុងកុងចំណាយពេលតែ៧ម៉ោងកន្លះ

នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០១៨ វេលាម៉ោង៨គត់ សំបុត្ររថភ្លើងល្បឿនលឿនក្វាងចូវ-សិនជិន-ហុងកុងចាប់ផ្ដើមលក់នៅក្នុងតំបន់ដីគោក និងតំបន់ហុងកុងនៃប្រទេសចិន ។ នៅថ្ងៃទី ២៣ ខែកញ្ញា កំណាត់ហុងកុងនៃខ្សែរថភ្លើងល្បឿនលឿនក្វាងចូវ-សិនជិន-ហុងកុងនឹងត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ។ ព្រឹត្តិការណ៍នេះជានិមិត្តសញ្ញានៃការតភ្ជាប់ខ្សែរថភ្លើងតំបន់ដីគោក និងហុងកុងប្រទេសចិន ។ ក្រុងគុនមីងជាក្រុងមួយដែលស្ថិតនៅតាមខ្សែរថភ្លើងល្បឿនលឿននេះ ដូច្នេះអ្នកដំណើរអាចជិះរថភ្លើងល្បឿនលឿនពីក្រុងគុនមីងទៅក្រុងហុងកុងដោយចំណាយពេលត្រឹមតែ៧ម៉ោងកន្លះចំណែកសំបុត្ររថភ្លើងលំដាប់លេខ២ពីក្រុងគុនមីង ទៅហុងកុងមានតម្លៃ ៧៥០,៥ យ៉ាន់ ។

ខ្សែរថភ្លើងក្វាងចូវ-សិនជិន-ហុងកុង ជាផ្នែកដ៏សំខាន់មួយនៃបណ្ដាញខ្សែរថភ្លើងល្បឿនលឿនចិន ។ ខ្សែរថភ្លើងល្បឿនលឿននេះមានប្រវែងសរុប១៤១គីឡូម៉ែត្រ ក្នុងនោះ ខ្សែរថភ្លើងលើដីគោកចិនមានប្រវែង ១១៥គីឡូម៉ែត្រ ចំណែកផ្នែកនៅហុងកុងមានប្រវែង ២៦ គីឡូម៉ែត្រ ។ កំណាត់ខ្សែរថភ្លើងពីក្រុងក្វាងចូវទៅសិនជិន និងហ្វូធានបានត្រូវដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅឆ្នាំ២០១១ និង ២០១៥រៀងខ្លួន ។ កំណាត់ខ្សែរថភ្លើងនៅហុងកុងត្រូវសាងសង់ដោយតំបន់រដ្ឋបាលពិសេសហុងកុង ដែលបានបើកការដ្ឋានសាងសង់នៅឆ្នាំ ២០១០ ។

ក្រោយពីកំណាត់ហុងកុងនៃខ្សែរថភ្លើងល្បឿនលឿនក្វាងចូវ-សិនជិន-ហុងកុងត្រូវដាក់ឱ្យប្រើប្រាស់ អ្នកដំណើរអាចជិះរថភ្លើងល្បឿនលឿនពីតំបន់ហុងកុងទៅក្រុងប៉េកាំង ស្យ៉ាងហៃ ស៊ីចាជួង ជឹងចូវ អ៊ូហាន ឆាងសា ហាងចូវ ណានឆាង ហ្វូចូវ ស្យាមិន សានធូវ គួយយ៉ាង គួយលីន និងគុនមីងជាដើម ដែលមានចំណតចំនួនជាង៤០ ។ នេះនឹងអាចផ្ដល់ការងាយស្រួលដល់ការធ្វើដំណើរពីតំបន់ហុងកុងទៅទីក្រុងផ្សេងៗលើដីគោកចិន ៕ **ដោយ ឆាវ ជា**

កំណត់ហេតុ: អ្នកដំណើរអាចឆែកមើលព័ត៌មានលើវេបសាយក្រុមហ៊ុនផ្លូវរថភ្លើងចិន (ដីគោកចិន: www.12306.cn តំបន់ហុងកុង: www.mtr.com.hk/highspeed) តាមទូរស័ព្ទរបស់ក្រុមហ៊ុនផ្លូវរថភ្លើងចិន (ដីគោកចិន: 86-12306 តំបន់ហុងកុង: 852-21200888) ឬតាមប្រកាសនៅស្ថានីយរថភ្លើងផ្សេងៗ ។ តម្លៃសំបុត្ររថភ្លើងនិងកាលវិភាគរថភ្លើងនឹងត្រូវប្រកាសជាសាធារណៈ។